សុន្ទរកថារបស់ **ឯកឧត្តម ហ៊ីដេហ៊ីសា ហូរីណូអ៊ុជិ**
ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
**១៣ កុម្ភៈ ២០១៧**

- **សូមគោរព ឯកឧត្តម ពេជ្រ វាសនា អគ្គនាយករងកិច្ចការរដ្ឋបាលនៃក្រសួងធនធានទឹក និងឧតុនិយម**
- **សូមគោរព វេជ្ជបណ្ឌិត គឹម សួរភិរុណ ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ចាម**
- **សូមគោរព វេជ្ជបណ្ឌិត ស្រី ស៊ីន ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ធំ**
- **សូមគោរព លោក កែវ វ៉យ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់**
- **សូមគោរព វេជ្ជបណ្ឌិត ជា អ៊ាកឆាយ ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំការលើ ខេត្តកំពង់ចាម**
- **សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខានៅថ្ងៃនេះ លើកិច្ចសន្យាផ្តល់ជំនួយចំនួនបីសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។

គម្រោងជំនួយទីមួយ ដែលមានថវិកាចំនួន**៨២,១៨០ដុល្លារអាមេរិក** សម្រាប់គម្រោងបំពាក់ឧបករណ៍បរិក្ខាពេទ្យនៅមន្ទីរពេទ្យបង្អែកចំការលើ ខេត្តកំពង់ចាម។ ថ្មីៗនេះ មន្ទីរពេទ្យបង្អែកនេះ មិនអាចធ្វើការវះកាត់បានទេ ដោយសារតែកង្វះឧបករណ៍សម្រាប់ធ្វើការវះកាត់។ គម្រោងនេះ នឹងផ្តល់ជូនឧបករណ៍បរិក្ខាពេទ្យមួយឈុត ដែលក្នុងនោះរួមមាន៖ ឧបករណ៍សម្រាប់វះកាត់ និងម៉ាស៊ីនធ្វើតេស្តឈាមជាដើម។ គម្រោងនេះត្រូវបានរំពឹងថា អ្នកជម្ងឺប្រមាណជា៦៦០នាក់ក្នុងមួយឆ្នាំនឹងអាចទទួលបាននូវសេវាវះកាត់នៅក្នុងមន្ទីរពេទ្យនេះ បន្ទាប់ពីបញ្ចប់គម្រោងនេះ។

គម្រោងជំនួយទីពីរ ដែលមានថវិកាចំនួន**៨៣,១៧៥ដុល្លារអាមេរិក** សម្រាប់គម្រោងសាងសង់អគារផ្នែកសង្គ្រោះបន្ទាន់ នៅមន្ទីរពេទ្យបង្អែកស្ទោង ខេត្តកំពង់ធំ។ អគារផ្នែកសង្គ្រោះបន្ទាន់ថ្មីនេះ នឹងបង្កើតបរិយាកាសសមរម្យមួយសម្រាប់ការព្យាបាលផ្នែកសង្គ្រោះបន្ទាន់ និងការថែទាំយ៉ាងយកចិត្តទុកដាក់ពីគ្រូពេទ្យ។ គម្រោងនេះត្រូវបានរំពឹងថា អ្នកជម្ងឺប្រមាណជា៦៦០នាក់ក្នុងមួយឆ្នាំ នឹងទទួលបានការព្យាបាលនៅក្នុងអគារផ្នែកសង្គ្រោះបន្ទាន់ថ្មីនេះ ហើយអ្នកមកពិគ្រោះជម្ងឺក្រៅប្រមាណជា ៣,១០០នាក់ក្នុងមួយឆ្នាំ ក៏នឹងទទួលបានគុណប្រយោជន៍ពីការផ្តល់សេវាពិនិត្យបែងចែកជម្ងឺដំបូងនៅក្នុងអគារថ្មីនេះផងដែរ។

គម្រោងជំនួយទីបី ដែលមានថវិកាចំនួន**៨២,៣៧៩ដុល្លារអាមេរិក** សម្រាប់គម្រោងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្របឹងកន្សែង ខេត្តពោធិ៍សាត់។ គម្រោងនេះ រួមមាន៖ ការស្តារប្រឡាយរង១ខ្សែប្រវែង ២,៣១០ម៉ែត្រ និងការសាងសង់ក្បាលប្រឡាយរង១កន្លែង និងសំណង់លូ៣កន្លែង។ គម្រោងនេះត្រូវបានរំពឹងថា ប្រជាកសិករប្រមាណជា៣,៣០០នាក់ នឹងទទួលបានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពលើដីស្រែ ហើយផ្ទៃដីដាំដុះរបស់ពួកគេ ក៏នឹងត្រូវបានពង្រីកកាន់តែច្រើនផងដែរ ក្រោមការស្តារប្រព័ន្ធធារាសាស្ត្រនេះ។

ខ្ញុំសង្ឃឹមថា គម្រោងទាំងបីដែលយើងបានចុះហត្ថលេខាផ្តល់ជំនួយនៅថ្ងៃនេះ នឹងត្រូវបានអនុវត្តទៅដោយរលូន និងប្រសិទ្ធភាពខ្ពស់ដោយដៃគូទទួលជំនួយទាំងបីនេះ។ ខ្ញុំសង្ឃឹមថា ឧបករណ៍បរិក្ខាពេទ្យ និងសំណង់អគារទាំងអស់ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវគង់វង្សយូរអង្វែង ដើម្បីអោយប្រជាជនកាន់តែច្រើនទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថា គម្រោងទាំងអស់នេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានស្រាប់រួចមកហើយរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា៕

**សូមអរគុណ!**